ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលប្រចាំឆ្នាំ២០២៥ នៃការអនុវត្តយុទ្ធនាការជំរុញនិងពន្លឿនរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ

*អ្នកនាំពាក្យក្រសួងយុត្តិធម៌* មានកិត្តិយសជម្រាបជូនសាធារណជនមេត្តាជ្រាបថា គិតចាប់ពី ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦ គឺមានរយៈពេល ២ឆ្នាំ ដែលក្រសួងយុត្តិធម៌បានអនុវត្តយុទ្ធនាការចំនួន ២ ព្រមពេលជាមួយគ្នា នៅក្នុងក្របខ័ណ្ឌនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌កម្ពុជាសំដៅពង្រឹង និងលើកកម្ពស់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ ដែលក្នុងនោះរួមមាន៖ (១)-យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និង (២)-យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ។ កាលពីព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦, **ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈបញ្ជាការដឹកនាំយុទ្ធនាការ បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារនៃការអនុវត្តយុទ្ធនាការទាំង ២ ប្រចាំឆ្នាំ២០២៥ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំនៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ នៅទូទាំងប្រទេស ដែល *អ្នកនាំពាក្យក្រសួងយុត្តិធម៌* សូមជម្រាបជូនសាធារណជនអំពីលទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធនាការទាំង ២ ខាងលើ ក្នុងឆ្នាំ២០២៥ ដូចខាងក្រោម៖

ទី១-ក្នុងឆ្នាំ ២០២៥ កន្លងមកនេះ, តុលាការគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេសបានចាត់ការសំណុំរឿងទាំងរឿងព្រហ្មទណ្ឌ ទាំងរឿងរដ្ឋប្បវេណី បានចំនួន **១៧២ ៣៩៩** ស្មើនឹង **៨០,៣០%** នៃសំណុំរឿងសរុបនៅទូទាំងប្រទេសចំនួន ២១៤ ៦៨៧។ នៅក្នុងចំណោមសំណុំរឿងសរុបទាំងនេះ រួមមាន៖

- សំណុំរឿងព្រហ្មទណ្ឌចំនួន ១០៩ ៩២១ តុលាការគ្រប់ជាន់ថ្នាក់ចាត់ការបានចំនួន ៩១ ៤០២ ស្មើនឹង ៨៣,១៥%
- សំណុំរឿងរដ្ឋប្បវេណីចំនួន ១០៤ ៧៦៦ តុលាការគ្រប់ជាន់ថ្នាក់ចាត់ការបានចំនួន ៨០ ៩៩៧ ស្មើនឹង ៧៧,៣១%។

គណៈបញ្ជាការដឹកនាំយុទ្ធនាការ បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលសម្រេចបាននេះ ដែលជាការបង្ហាញពីការយកចិត្តទុកដាក់ ប្រកបដោយការទទួលខុសត្រូវខ្ពស់របស់តុលាការគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស ក្នុងការដោះស្រាយរឿងក្តីបានឆាប់រហ័សជូនប្រជាពលរដ្ឋ។



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

**ទី២**-គិតចាប់តាំងពីពេលប្រកាសបើកយុទ្ធនាការ គណៈបញ្ជាការដឹកនាំយុទ្ធនាការបានប្រកាសទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋទាំងអស់ ដែលយល់ឃើញថា ចំណាត់ការរបស់តុលាការលើសំណុំរឿងរបស់ខ្លួនមានភាពមិនប្រក្រតី។ ក្នុងឆ្នាំ ២០២៥ កន្លងទៅនេះ លេខាធិការដ្ឋាននៃគណៈបញ្ជាការដឹកនាំយុទ្ធនាការទទួលបានពាក្យបណ្ដឹងសរុប ចំនួន **១ ៧៥៩ បណ្ដឹង** ដោយក្នុងនោះ រួមមាន៖

(១)- ករណីស្នើសុំជំរុញ និងពន្លឿនការដោះស្រាយរឿងក្ដីនៅតាមតុលាការមានចំនួន **៦៣៨ ករណី** ស្មើនឹង **៣៦,២៧%** ហើយតុលាការបានដោះស្រាយចប់សព្វគ្រប់បាន **១០០%**។

(២)- ពាក្យបណ្ដឹងស្នើសុំឱ្យមានការត្រួតពិនិត្យអំពីភាពមិនប្រក្រតី មានចំនួន **១ ១២១ ករណី** (ក្នុងនោះរួមមានបណ្ដឹងសល់ពីឆ្នាំ២០២៤ ចំនួន **២៤៣ ករណី**) ស្មើនឹង **៦៣,៧២%** ប៉ុន្តែ ពាក្យបណ្ដឹងចំនួន ៨ ករណី ត្រូវបានតម្កល់ឥតចាត់ការ និងពាក្យបណ្ដឹងចំនួន ២៦ ករណី ត្រូវបានម្ចាស់បណ្ដឹងដកពាក្យបណ្ដឹងវិញ ដូច្នេះ ពាក្យបណ្ដឹងដែលនៅសល់ដែលត្រូវចាត់ការមានចំនួន **១ ០៨៧ ករណី**។ គណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ចាត់ការរួចបានចំនួន **៨៦៧ ករណី** ស្មើនឹង **៧៩,៧៦ %**។ ក្នុងចំណោមសំណុំរឿងដែលបានចាត់ការ៖

- **ត្រូវបានរកឃើញថា "ពុំមានភាពមិនប្រក្រតី"** ចំនួន ៨១៤ **ករណី** ស្មើនឹង ៩៣,៨៩% ក្នុងនោះ តុលាការសម្រេចដោយមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវ និងច្បាស់លាស់ ចំនួន ៤០៣ **ករណី** ស្មើនឹង ៤៦,៤៨%, សំណុំរឿងដែលកំពុងស្ថិតក្នុងចំណាត់ការរបស់តុលាការ ហើយម្ចាស់បណ្ដឹងគ្រាន់តែបារម្ភថាអាចមានភាពមិនប្រក្រតី ចំនួន ៤០២ **ករណី** ស្មើនឹង ៤៦,៣៧% និងករណីគូភាគីបានយល់ព្រមសម្រុះសម្រួលគ្នា ចំនួន ៩ **ករណី** ស្មើនឹង ១,០៤%។
- **មានតម្រុយសង្ស័យថា "អាចមានភាពមិនប្រក្រតី"** ចំនួន ៥៣ **ករណី** ស្មើនឹង ៦,១១% (មានការថយចុះ បើធៀបនឹងឆ្នាំ ២០២៤ កន្លងទៅ ដែលមាន **៦,៧២%**) ក្នុងនោះ បានចាត់ឱ្យមានការចុះធ្វើអធិការកិច្ច ចំនួន **៣៦ ករណី** ស្មើនឹង ៤,១៥%, ភាគីអាចស្នើសុំឱ្យមានការជំនុំជម្រះសាជាថ្មី ចំនួន **៧ ករណី** ស្មើនឹង ០,៨១%, ធ្វើអធិបញ្ញាឱ្យចោទប្រកាន់ ចំនួន **៧ ករណី** ស្មើនឹង ០,៨១% និងផ្ទេរសមត្ថកិច្ច ចំនួន ៣ **ករណី** ស្មើនឹង ០,៣៥%។ ក្នុងចំណោមករណី ដែលបានចុះអធិការកិច្ចទាំង ៣៦ ករណី, បានរកឃើញមានភាពមិនប្រក្រតី ហើយបានបញ្ជូនទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន **២៧ ករណី** ដែលក្នុងនោះ មានពាក់ព័ន្ធនឹងចៅក្រម ចំនួន ៤៤ រូប និងព្រះរាជអាជ្ញា ចំនួន **១៧** រូប។
- សំណុំរឿងនៅសល់ និងកំពុងចាត់ការដោយគណៈបញ្ជាការដឹកនាំយុទ្ធនាការមានចំនួន ២២០ ករណី ស្មើនឹង ២០,២៤ % នៃចំនួនសំណុំរឿងសរុប ដែលគណៈកម្មការដឹកនាំ និងអនុវត្តយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការទទួលបាន។

ផ្អែកលើទិន្នន័យខាងលើ ដោយធៀបនឹងសំណុំរឿងទូទាំងប្រទេស ដែលមានចំនួន **២១៤ ៦៨៧ ករណី** ប្រជាពលរដ្ឋដែលយល់ថាមានភាពមិនប្រក្រតីចំពោះចំណាត់ការលើសំណុំរឿងរបស់ខ្លួន ហើយបានដាក់ពាក្យបណ្ដឹងមកកាន់លេខាធិការដ្ឋាននៃគណៈបញ្ជាការដឹកនាំយុទ្ធនាការ មានចំនួន **១ ៧៥៩ បណ្ដឹង** ស្មើនឹង ០,៨១% នៃសំណុំរឿងសរុបទូទាំងប្រទេស។ ជាលទ្ធផល ក្នុងចំណោមសំណុំរឿងសរុបនៅទូទាំងប្រទេស សំណុំរឿងដែលត្រូវបានរកឃើញតម្រុយសង្ស័យថាអាចមានភាពមិនប្រក្រតីមានចំនួនត្រឹមតែ **៥៣ ករណី** គឺស្មើនឹង ០,០២% នៃសំណុំរឿងសរុបទូទាំងប្រទេសប៉ុណ្ណោះ ដែលលទ្ធផលនេះបានឆ្លុះបញ្ចាំង និងបញ្ជាក់យ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់តុលាការលើការពង្រឹងគុណភាពនៃការសម្រេចសេចក្ដីរបស់ខ្លួន។

**ទី៣**-ក្នុងក្របខ័ណ្ឌនៃយុទ្ធនាការ, លេខាធិការដ្ឋាននៃគណៈបញ្ជាការដឹកនាំយុទ្ធនាការ ក៏បានធ្វើការសម្របសម្រួលផ្ដល់មេធាវីស្ម័គ្រចិត្ត ដែលជាទីប្រឹក្សាក្រសួងយុត្តិធម៌ចំនួន **១០៧ រូប** ដើម្បីជួយការពារក្ដីដោយឥតគិតថ្លៃ ដល់ប្រជាពលរដ្ឋដែលបានដាក់ពាក្យស្នើសុំមកយុទ្ធនាការ។

**ទី៤**-ចំពោះសំណុំរឿងអាទិភាពទាំង ៤ ដែលរួមមាន៖ សំណុំរឿងអត្រានុកូលដ្ឋាន, សំណុំរឿងចរាចរណ៍, សំណុំរឿងគ្រឿងញៀន និងសំណុំរឿងក្មេងទំនើង, សាលាដម្រះក្ដី និងអង្គការអយ្យការអមសាលាដម្រះក្ដី បានចាត់ការ និងទទួលបានលទ្ធផលដូចខាងក្រោម៖

(១)- **សំណុំរឿងអត្រានុកូលដ្ឋាន** ទាំងចាស់ ទាំងថ្មី ដែលមានចំនួន **៥៧ ០០៨ ករណី** ត្រូវបានតុលាការចាត់ការរួច **៩៧,៨១%**។ ចំណាត់ការលឿននិងត្រឹមត្រូវដោយគ្មានភាពមិនប្រក្រតីលើសំណុំរឿងអត្រានុកូលដ្ឋាននេះ បានទទួលនូវការស្វាគមន៍ និងការថ្លែងអំណរគុណជាបន្តបន្ទាប់ ពីសំណាក់ប្រជាពលរដ្ឋ ហើយការទុកចិត្តកាន់តែខ្លាំងលើចំណាត់ការរបស់តុលាការលើសំណុំរឿងអត្រានុកូលដ្ឋាននេះ ក៏បានធ្វើឱ្យប្រជាពលរដ្ឋដាក់ពាក្យសុំកែតម្រូវអត្រានុកូលដ្ឋានកាន់តែច្រើនមកតុលាការ។ គណៈបញ្ជាការដឹកនាំយុទ្ធនាការបានជំរុញឱ្យតុលាការទូទាំងប្រទេសនៅតែបន្តយកចិត្តទុកដាក់ក្នុងការទទួលដោះស្រាយសំណុំរឿងអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស និងត្រឹមត្រូវជាបន្តទៀត។

(២)- **សំណុំរឿងចរាចរណ៍** ទាំងចាស់ ទាំងថ្មី ដែលមានចំនួន **៥ ១៩២ ករណី** ត្រូវបានតុលាការចាត់ការរួច ៨៣,៨៤%។ គណៈបញ្ជាការដឹកនាំយុទ្ធនាការ ក៏បានពិនិត្យឃើញផងដែរថា ការដោះស្រាយសំណងជូនដល់ជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ ត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់ និងឆាប់រហ័ស។ ទន្ទឹមនេះ, អ្នកបើកបរ ដែលមានកំហុសទៅនឹងច្បាប់ចរាចរណ៍ និងបានបង្កគ្រោះថ្នាក់បណ្ដាលឱ្យអ្នកដទៃស្លាប់ គឺត្រូវតែទទួលខុសត្រូវតាមច្បាប់ដោយម៉ឺងម៉ាត់ និងដោយត្រឹមត្រូវតាមច្បាប់ ហើយពាក្យថា "**បុកគេស្លាប់ បង់លុយហើយរួចខ្លួន**" គឺលែងមានទៀតហើយ នៅក្នុងក្របខ័ណ្ឌនៃការកែទម្រង់នេះ។ ទោះជាយ៉ាងណា, គណៈបញ្ជាការដឹកនាំយុទ្ធនាការសង្កេតឃើញថា មានករណីកាន់តែច្រើនដែលអ្នកបង្កគ្រោះថ្នាក់ចរាចរណ៍មានសុឆន្ទៈក្នុងការផ្ដល់សំណងជូនជនរងគ្រោះដោយឆាប់រហ័ស ទោះបីដឹងថាការសងសំណងរដ្ឋប្បវេណីនេះនឹងមិនអាចឱ្យខ្លួនរួចផុតពីការចោទប្រកាន់ខាងព្រហ្មទណ្ឌ។

(៣)- **សំណុំរឿងគ្រឿងញៀន** ទាំងចាស់ ទាំងថ្មី ដែលមានចំនួន ២៤ ០២២ ករណី ត្រូវបានតុលាការទូទាំងប្រទេសចាត់ការរួចរាល់បាន ៨៦,៤៧%។ ពាក់ព័ន្ធនឹងសំណុំរឿងគ្រឿងញៀននេះ, សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី គ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស នៅតែបន្តប្រកាន់ខ្ជាប់នូវគោលការណ៍ "**តម្លាភាព**" ដោយបានចេញសេចក្តីប្រកាសព័ត៌មានជាប់ជាប្រចាំ ចំពោះចំណាត់ការសំណុំរឿងគ្រឿងញៀននៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់អយ្យការ និងតុលាការ ដើម្បីបញ្ចៀសបាននូវការមិនទុកចិត្តគ្នាក្នុងចំណោមស្ថាប័នអនុវត្ត និងម្យ៉ាងទៀត ដើម្បីធានាប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តច្បាប់ប្រកបដោយការទទួលខុសត្រូវពីសំណាក់ស្ថាប័នអនុវត្តច្បាប់ទៅកាន់សាធារណជន។ បន្ថែមពីនេះ, ចំណាត់ការសំណុំរឿងគ្រឿងញៀន ត្រូវបានធ្វើឡើងដោយប្រកាន់ខ្ជាប់នូវអភិក្រម "**ម៉ឺងម៉ាត់ និងត្រឹមត្រូវតាមច្បាប់**" និង "**ស្អាតស្អំ**" ដោយហេតុមកដល់ពេលនេះ ពុំទាន់រកឃើញថាមានភាពមិនប្រក្រតីណាមួយនៅឡើយ ពាក់ព័ន្ធនឹងចំណាត់ការលើសំណុំរឿងគ្រឿងញៀន។ ទន្ទឹមនេះ, ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពរបស់សង្គមជាតិ ព្រមទាំងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ, គណៈបញ្ជាការដឹកនាំយុទ្ធនាការ បានបន្តអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ចាកឆ្ងាយពីគ្រឿងញៀន និងចៀសវាងនូវរាល់សកម្មភាពទាំងឡាយណាដែលបង្កអន្តរាយដល់គ្រួសារ និងសង្គមជាតិ និងលើកទឹកចិត្តសូមឱ្យមានការបន្តផ្តល់កិច្ចសហការរាយការណ៍ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ពីសំណាក់សាធារណជន, បណ្តាញសារព័ត៌មាន ក៏ដូចជា ស្ថាប័នពាក់ព័ន្ធ ដើម្បីបន្តអនុវត្តច្បាប់ដោយម៉ឺងម៉ាត់ នៅក្នុងសំណុំរឿងគ្រឿងញៀននេះ។

(៤)- នៅក្នុង**សំណុំរឿងក្មេងទំនើង**, គណៈបញ្ជាការដឹកនាំយុទ្ធនាការ បានពិនិត្យឃើញថា តុលាការបានអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់ ហើយវិធានការម៉ឺងម៉ាត់នេះ បានចូលរួមចំណែកក្នុងការធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ដោយយើងសង្កេតឃើញជារួមថា បច្ចុប្បន្ននេះ សកម្មភាពក្មេងទំនើងនៅសល់តិចតួចតែប៉ុណ្ណោះ។ ជាថ្មីម្តងទៀត, គណៈបញ្ជាការដឹកនាំយុទ្ធនាការ បានអំពាវនាវឱ្យឪពុកម្តាយ ព្រមទាំងអាណាព្យាបាលទាំងអស់ ខិតខំតាមដាន អប់រំ និងទូន្មានប្រៀនប្រដៅកូនៗឱ្យដើរតាមគន្លងត្រឹមត្រូវ ដើម្បីក្លាយខ្លួនជាពលរដ្ឋល្អសម្រាប់សង្គមជាតិ និងអំពាវនាវដល់យុវជនទាំងអស់ ដែលជាទំពាំងស្នងឫស្សីរបស់ប្រទេសជាតិ ប្រកាន់ខ្ជាប់នូវវិន័យ សីលធម៌ និងសេចក្តីថ្លៃថ្នូរ ហើយចៀសវាងនូវរាល់សកម្មភាពទាំងឡាយណា ដែលបង្កអន្តរាយដល់ខ្លួន គ្រួសារ និងសង្គមជាតិ ឬអំពើល្មើសច្បាប់ ដែលអាចប្រឈមនឹងការជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ។

(៥)- ក្រៅពីសំណុំរឿងអាទិភាពទាំង ៤ ខាងលើ គណៈបញ្ជាការដឹកនាំយុទ្ធនាការបានសម្រេចដាក់សំណុំរឿងអាទិភាពចំនួនមួយបន្ថែមទៀត គឺសំណុំរឿងពាក់ព័ន្ធនឹង**ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា** ដោយសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស នឹងចេញសេចក្តីប្រកាសព័ត៌មានជាប់ជាប្រចាំ ចំពោះចំណាត់ការសំណុំរឿងឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់អយ្យការ

និងតុលាការ ដើម្បីបញ្ចៀសបាននូវការមិនទុកចិត្តគ្នាក្នុងចំណោមស្ថាប័នអនុវត្ត និងម្យ៉ាងទៀត ដើម្បីធានាប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តច្បាប់ប្រកបដោយការទទួលខុសត្រូវពីសំណាក់ស្ថាប័នអនុវត្តច្បាប់ទៅកាន់សាធារណជន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន និងសូមបន្តលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលយល់ឃើញថា ចំណាត់ការរបស់តុលាការលើសំណុំរឿងរបស់ខ្លួនមានភាពយឺតយ៉ាវ ឬមានភាពមិនប្រក្រតី សូមដាក់ពាក្យបណ្ដឹងមកយន្តការផ្លូវការនៃយុទ្ធនាការទាំង ២ របស់ក្រសួងយុត្តិធម៌ តាមរយៈលេខទូរស័ព្ទ និង QR Code ដែលមានភ្ជាប់មកជាមួយ។

លេខទូរស័ព្ទ 099 444 181

ថ្ងៃសុក្រ ១៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦

**អ្នកនាំពាក្យក្រសួងយុត្តិធម៌**